JICA Cambodia Office - JICA カンボジア事務所

June 22 at 2:49 PM ·

**[អបអរសាទរ ទិវាគិលានុបដ្ឋាកអន្តរជាតិ ២០២២ / Celebration of International Nurses Day's Event 2022]**

------------------------------

**នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល និង សមាគមគិលានុបដ្ឋាកកម្ពុជាបានរៀបចំកម្មវិធីទិវាគិលានុបដ្ឋាកអន្តរជាតិ ក្រោមប្រធានបទ "គិលានុបដ្ឋាករួមគ្នាធ្វើឲ្យប្រសើរឡើង នូវការថែទាំនិងការគោរពសិទ្ធិអតិថិជនដើម្បីធានាបាននូវសុខភាពជាសកល" នៅសណ្ឋាគារភ្នំពេញ និង តាមប្រព័ន្ធអនឡាញ (Zoom)។**
**ព្រឹត្តិការណ៍នេះមានអ្នកចូលរួមប្រមាណ ២០០នាក់ រួមទាំងតំណាងអង្គការសុខភាពពិភពលោក (WHO) USAID ទីភ្នាក់ងារថៃកា និងអង្គការអន្តរជាតិជាច្រើនផ្សេងទៀត ក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជា និងបានថ្លែងសន្ទរកថាបើកអង្គពិធីទាំងមូលនេះផងដែរ។**
**ប្រធានបទស្តីពី «ការវិនិយោគលើគិលានុបដ្ឋាកៈ ការអភិវឌ្ឍធនធានមនុស្ស» ក៏បានលើកឡើងតាមរយៈការធ្វើបទបង្ហាញរបស់លោកស្រីវេជ្ជបណ្ឌិត Hiura Mizue ប្រធានទីប្រឹក្សាគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា (Strings project) របស់ JICA ដែលគោលដៅសំខាន់នៃកម្មវិធីនេះគឺដើម្បីអបអរសាទរសមិទ្ធិផលរបស់គិលានុបដ្ឋាកក្នុងរយៈពេលកន្លងមក និងដើម្បីផ្តល់ឱកាសសម្រាប់ការចែករំលែកបទពិសោធន៍ និងការអភិវឌ្ឍន៍វិជ្ជាជីវៈជាបន្តបន្ទាប់។**

**On 16th June, the Department of Hospital Services of Ministry of Health and Cambodian Association of Nurses (CAN) co-organized the 2022 International Nurses Day Event under the theme, "Invest in nursing and respect rights to secure global health" at Phnom Penh Hotel and via Zoom Online Meeting as a hybrid style.**
**Around 200 participants including WHO, JICA, USAID and other international organization, participated in the event. H.E. Prof. MAM Bunheng, Minister of Ministry of Health made the opening speech.**
**Dr. HIURA Mizue, Chief Advisor of the Project for Strengthening In-Service Training System in Cambodia (Strings Project), was also given the floor to present on the topic of "Investing in Nursing: Human Resource Development" for Celebrating nurses' accomplishments over the years and providing opportunities for experience sharing and further professional development which were the main goals of this special event.**

**#Strings #IND2022**

**Credited: Strings Project**










